HIV/AIDS YOUR QUESTIONS ANSWERED

CAMBODIAN

# *HIV/AIDS*
# ចម្លើយទៅនឹង
# សំណួររបស់អ្នក

# តើ *AIDS* ជាអ្វីទៅ?

**AIDS (អេដស៍) ជាអក្សរកាត់នៃពាក្យ Acquired Immune Deficiency Syndrome (អាការរោគនៃការទន់ខ្សោយប្រព័ន្ធបន្សាំរោគដែលទទួលបាន)។**

Acquired (ទទួលបាន) មានន័យថា មិនទទួលជំណែល។

Immune Deficiency (ការទន់ខ្សោយប្រព័ន្ធបន្សាំរោគ) មានន័យថា ការខូចខាតដល់ប្រព័ន្ធការពារបន្សាំរោគរបស់រាងកាយ។

Syndrome (អាការរោគ) សំដៅអំពីការប្រមូលផ្តុំជម្ងឺទាំងឡាយ ដែលប្រហែលជាមានទំនាក់ទំនងជាមួយនឹងជម្ងឺមួយទៀត។ នៅក្នុងករណីនេះ ជម្ងឺទាំងឡាយដែលឆ្លៀតទាញយកប្រយោជន៍នៃការដួលរលំរបស់ប្រព័ន្ធបន្សាំរោគរាងកាយ ត្រូវបានប្រើដើម្បីផ្តល់អត្ថន័យដល់ផ្នែកផ្តើមនៃ AIDS។

# តើអ្វីដែលបណ្តាលឲ្យមាន *AIDS*?

**វីរុសជាកត្តាធ្វើឲ្យមាន AIDS ។ វីរុសនេះហៅថា វីរុសធ្វើឲ្យទន់ខ្សោយដល់ការបន្សាំរោគនៃមនុស្ស (Human Immunodeficiency Virus) ឬ HIV ។**

HIV វាយប្រហារទៅលើប្រព័ន្ធការពាររាងកាយ ធ្វើឲ្យកើតជម្ងឺឆ្លងនិងមហារីកផ្សេងៗ។

ចំនួនប្រហែល 50 ភាគរយនៃអ្នកមាន HIV នឹងកើតមានជម្ងឺឆ្លង និង/ឬ មហារីកធ្ងន់ធ្ងរទាំងឡាយ (AIDS) នៅក្នុងកម្លុងពេល 10 ឆ្នាំនៃពេលឆ្លងវីរុសនេះ។ អ្នកខ្លះដែលមាន AIDS តាមទំរង់មិនសូវជាខ្លាំងក្លាទាំងនេះ ប្រហែលជាកើតមានជម្ងឺកាន់តែធ្ងន់ធ្ងរឡើងនៅពេលក្រោយមកទៀត។ អ្នកមាន HIV មួយចំនួនតូច មិនមានបង្ហាញនូវការចុះដុនដាបនៃសុខភាពរបស់គេឡើយ សូម្បីតែនៅក្រោយពេល 10 ឆ្នាំក៏ដោយ។

# តើវិជ្ជមាននឹងអង្គបដិបក្ខ *HIV* *(HIV antibody positive)* មានន័យអ្វីទៅ?

អ្នកដែលឆ្លង HIV កើតមានអង្គបដិបក្ខ(ប្រូតេអ៊ីនដែលរាងកាយបង្កើតឡើងសម្រាប់ប្រយុទ្ធនឹងមេរោគ)។ អង្គបដិបក្ខទៅនឹង HIV ជាធម្មតាអាចតាមរកឃើញបាននៅក្នុងកម្លុងពេលពីរអាទិត្យទៅបីខែ បន្ទាប់ពីឆ្លងវីរុសនេះមក។ គេអាចតាមរកឃើញអង្គបដិបក្ខទាំងនេះបានដោយការធ្វើតេស្តឈាម ដែលគួរមានការធ្វើតេស្តជាបន្ថែមទៀតនៅពេល 12 អាទិត្យ ក្រោយពីនោះ។

នៅពេលដែលអង្គបដិបក្ខត្រូវបានរកឃើញនៅក្នុងឈាមនៃអ្នកដែលឆ្លង HIV គេនិយាយថា អ្នកទាំងនេះវិជ្ជមាននឹងអង្គបដិបក្ខ HIV ។

ជនណាដែលវិជ្ជមាននឹងអង្គបដិបក្ខ HIV ប្រហែលជាមិនមាន AIDS ទេ ប៉ុន្តែអ្នកទាំងនោះពាំនាំវីរុសនេះនិងអាចចម្លងវាតាមរយៈឈាមឬការរួមសង្វាសដែលមិនមានការការពារ។

# តើមានការធ្វើតេស្តអ្វីទៅសម្រាប់រក មើល *AIDS?*

ការឆ្លងកើត HIV មិនមែនមានន័យថា អ្នកនោះមាន AIDS ឡើយ។ រោគវិនិច្ឆ័យនៃ AIDS ត្រូវបានកើតឡើងនៅពេលមានការខូចខាតប្រព័ន្ធបន្សាំរោគតែប៉ុណ្ណោះ ដែលបណ្តាលឲ្យកើតជម្ងឺឆ្លងនិងមហារីក។ រោគវិនិច្ឆ័យប្រហែលជាត្រូវការឲ្យមានការធ្វើតេស្តតាមមន្ទីរពិសោធន៍ពិសេសមួយចំនួន។

ការធ្វើតេស្តលើអង្គបដិបក្ខ HIV បង្ហាញថាតើនរណាមួយមានឆ្លងវីរុសនេះដែរឬទេ។ ការធ្វើតេស្តនេះមិនប្រាប់គេថា គេមាន AIDS ឬនឹងបន្តទៅជាកើតមាន AIDS នោះទេ។

នៅពេលអ្នកមានការធ្វើតេស្ត វាជាការសំខាន់ណាស់ក្នុងការទទួលឱវាទនៅមុននិងក្រោយការធ្វើតេស្តនេះ។

# តើគេអាចព្យាបាលឬធ្វើឲ្យ *AIDS* ជា សះស្បើយដែរឬទេ?

គ្រាសព្វថ្ងៃនេះ ពុំមានថ្នាំចាក់ការពារឬព្យាបាល AIDS ទេ។ ទោះជាយ៉ាងណាក្តីក៏មានការព្យាបាលថ្មីប្រើថ្នាំគួបផ្សំគ្នា ដែលអាចតទល់នឹង HIV ហើយដែលត្រូវបានយល់ថាអាចពន្យារការរីកចំរើនឲ្យទៅជា AIDS ។

ការព្យាបាលសម្រាប់ជម្ងឺជាក់លាក់ជាច្រើនដែលទាក់ទងនឹង AIDS ក៏មានផងដែរ។

ថ្នាំនិងការព្យាបាលថ្មីទាំងឡាយ កំពុងទទួលការសាកល្បងនៅគ្រប់ពេលទាំងអស់។

# តើអ្នកឆ្លង *HIV* តាមរបៀបណា?

HIV អាចចម្លងតាម:

- ការរួមសង្វាសមិនមានការការពារ (តាមគូទឬយោនី) ជាមួយនឹងអ្នកកើតរោគ។
- ឈាមនៃអ្នកមានរោគចូលទៅក្នុងដំណើរឈាមរត់នៃជនមួយទៀត (ដូចជានៅពេលដែលអ្នកប្រើថ្នាំញៀនដោយការចាក់ម្ជុល ប្រើម្ជុល សឺរាំងនិងសំភារៈចាក់ដទៃទៀតរួមគ្នា)។
- ម្តងម្កាលគឺឆ្លងពីម្តាយដែលកើតរោគទៅកាន់ទារកក្នុងកម្លុងពេលមានផ្ទៃពោះ ពេលសម្រាលកូន ឬតាមរយៈទឹកដោះម្តាយ។

នៅប្រទេសអូស្ត្រាលី HIV ឆ្លងជាទូទៅបំផុតដោយសារការរួមសង្វាសដោយពុំមានប្រើស្រោមការពារ (condom) និងតាមរយៈការប្រើរួមគ្នានូវម្ជុល សឺរាំង និងសំភារៈចាក់ដទៃទៀត ដោយអ្នកប្រើថ្នាំញៀនចាក់តាមម្ជុល។

គេពុំមានភស្តុតាងឡើយដែលថា HIV ឆ្លងតាមរយៈការទាក់ទងក្នុងសង្គមឬក្នុងគ្រួសារជាធម្មតា។

## តើខ្ញុំអាចឆ្លង *HIV* ពីទឹកមាត់, សត្វ, បង្គន់, សត្វល្អិត, ការចាប់ដៃរលាក់, ចានថ្ម, អាងហែលទឹក ។ល។និង ។ល។ ដែរឬទេ?

គេមិនមានភស្តុតាងនៅនឹងទីកន្លែងណាមួយក្នុងពិភពលោកដើម្បីផ្តល់មតិថា HIV ឆ្លងរាលដាលតាមរយៈវិធីណាមួយក្នុងចំណោមវិធីទាំងនេះឡើយ។ HIV មិនអាចឆ្លងតាមរយៈការទាក់ទងក្នុងសង្គម ដូចជាការឱប ការចាប់ដៃរលាក់ ការប្រើសំភារៈក្នុងផ្ទះរួមគ្នា ផើងអង្គុយនៃបង្គន់ អាងហែលទឹក ឬសត្វចិញ្ចឹមលេង។

ថ្នាំធ្វើឲ្យសយ៉ាងសាមញ្ញប្រើតាមផ្ទះ ឬក៏សាប៊ូនិងទឹកក្តៅឧណ្ហៗអាចសម្លាប់ HIV ។

## តើអ្វីជាការរួមសង្វាសមានសុវត្ថិភាពឬកាន់តែមានសុវត្ថិភាព?

ការរួមសង្វាសមានសុវត្ថិភាពឬកាន់តែមានសុវត្ថិភាពមានន័យថា សកម្មភាពរួមសង្វាសដែលទឹកកាម សារធាតុឬឈាមបញ្ចេញដោយយោនី ពុំមានប្តូរគ្នារវាងដៃគួរួមសង្វាស។ សកម្មភាពរួមសង្វាសដែលមានលទ្ធភាពមានគ្រោះថ្នាក់ខ្លាំង រួមមានការរួមសង្វាសតាមគូទឬយោនីដែលមិនមានការការពារ ជាមួយនឹងដៃគូដែលមាន HIV ។

សកម្មភាពរួមសង្វាសមានសុវត្ថិភាពរួមមាន ការកាន់ស្ទាបអង្អែលអង្គជាតិ (masturbation )ទៅវិញទៅមក ការប៉ះស្ទាបគ្នា ការឱបថ្នាក់ថ្នម ការប៉ះកកិតរវាងរាងកាយ និងការធ្វើសរសៃធ្វើឲ្យស្រើបស្រាល។

ការប្រើស្រោមការពារឲ្យបានសមស្របក្នុងកម្លុងការរួមសង្វាស (តាមគូទនិងយោនី) នឹងកាត់បន្ថយជាខ្លាំងដល់លទ្ធភាពមានគ្រោះថ្នាក់នៃការឆ្លង HIV ។ ស្រោមការពារត្រូវតែប្រើឲ្យបានត្រឹមត្រូវនិងជាមួយនឹងប្រេងរំអិលផ្អែកលើជាតិទឹកយ៉ាងច្រើន។ ប្រេងរំអិលផ្អែកលើជាតិប្រេងកាតឬប្រេង នឹងបណ្តាលឲ្យស្រោមការពាររហែក។

# តើការរួមសង្វាសដោយប្រើមាត់ជាវិធីចម្លង *HIV* ឬ?

គេពុំមានភស្តុតាងដើម្បីផ្តល់មតិថា ការរួមសង្វាសដោយប្រើមាត់ គឺជាឥរិយាបថបង្កលទ្ធភាពមានគ្រោះថ្នាក់ខ្លាំងសម្រាប់ចម្លង HIV ទេ  ប៉ុន្តែអ្នកគួរប្រើស្រោមការពារ។

នៅពេលដែលដៃគូណាមួយមានពងទឹកថ្លាតូចៗនៅលើស្បែក (herpes) ដំបៅឬអញ្ចាញធ្មេញចេញឈាម  វាជាការប្រសើរដើម្បីចៀសវាងការរួមសង្វាសដោយប្រើមាត់ ឬចេញទឹកកាមទៅក្នុងមាត់។

# តើការថើបជញ្ជក់មាត់យ៉ាងជ្រៅគឺជា វិធីចម្លង *HIV* ឬ?

ទឹកមាត់នៃអ្នកមានរោគ មានវីរុស HIV មួយចំនួនតូចតែប៉ុណ្ណោះ។ ដើម្បីកើតមានការឆ្លងរោគ គេនឹងត្រូវការទឹកមាត់តាមបរិមាណយ៉ាងច្រើនជាខ្លាំងឲ្យចូលទៅក្នុងដំណើរឈាមរត់។ ហេតុដូច្នេះការថើបជញ្ជក់មាត់យ៉ាងជ្រៅ ពុំមែនជាឥរិយាបថបង្កលទ្ធភាពមានគ្រោះថ្នាក់សម្រាប់ចម្លង HIV ទេ។

# តើអ្វីជាលទ្ធភាពនៃអាការរោគរបស់ *AIDS?*

អាការរោគជាធម្មតាខ្លះនៃជម្ងឺទាក់ទងនឹង HIV គឺ:

- ការហត់នឿយយ៉ាងខ្លាំងក្លានិងជាប់ជានិច្ច។
- គ្រុនក្ដៅ គ្រុនរងា និងការបែកញើសនៅពេលយប់ជារឿយៗ។
- ការចុះទម្ងន់យ៉ាងលឿនដោយពុំមានមូលហេតុច្បាស់។
- ការហើមក្រពេញលសិកានៅនឹងក ក្លៀក ឬកន្លែងក្រលៀន។
- ស្នាមពណ៌ស ឬស្នាមមិនធម្មតានៅក្នុងមាត់។
- ស្នាមឬស្នាមពកលើស្បែក (ហើបឬក៏សំប៉ែត ជាធម្មតាមិនឈឺទេ ហើយឡើងពណ៌ស្វាយបន្តិច)។
- ក្អកមិនបាត់ឬក្អកស្ងួត។
- រាគរូស។
- ការថយចុះនៃការឃ្លានចំណីអាហារ។

អាការរោគទាំងនេះមានជាទូទៅចំពោះជម្ងឺមួយចំនួន រួមមានជម្ងឺដែលទាក់ទងនឹង HIV ។ បើអ្នកមានសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងនេះ (ឬការរួមគ្នាណាមួយនៃសញ្ញាទាំងនេះ) អស់ពេលមួយខែឬក៏យូរជាងនេះដោយពុំមានមូលហេតុច្បាស់លាស់ អ្នកគួរទៅជួបពិភាក្សាជាមួយវេជ្ជបណ្ឌិតអ្នក។

# តើអ្វីជាលទ្ធភាពមានគ្រោះថ្នាក់ឆ្លង *HIV* តាមរយៈការចាក់បញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យ?

ចាប់តាំងពីខែឧសភា ឆ្នាំ 1985 មក ការធ្វើអំណោយឈាមទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី ត្រូវបានឆែកពិនិត្យរកមើលអង្គបដិបក្ខ HIV ។ បើអ្នកមានការចាក់បញ្ចូលឈាម រវាងឆ្នាំ 1980 ដល់ខែឧសភា ឆ្នាំ 1985 អ្នកប្រហែលជាមានបំណងទៅជួបនិយាយជាមួយវេជ្ជបណ្ឌិតអ្នក អំពីការធ្វើតេស្តរកមើលអង្គបដិបក្ខ HIV ។

# តើខ្ញុំអាចឆ្លង *HIV* ឬទេ នៅពេលធ្វើ អំណោយឈាម?

មិនអាចឆ្លងទេ។ ម្ជុល កញ្ចប់ ប្រដាប់ជូត កាំបិតចាក់ម្រាមដៃ និងវត្ថុទាំងឡាយឥចីវ៉ងនោះ មិនដែលប្រើសាជាថ្មីទេ។

# តើរដ្ឋាភិបាលកំពុងធ្វើអ្វីទៅអំពី *HIV/AIDS*?

រដ្ឋាភិបាលសហព័ន្ធនិងរដ្ឋ កំពុងធ្វើសហការជាមួយអង្គការផ្អែកលើសហគមន៍ ដើម្បីប្រយុទ្ធនឹង HIV/AIDS ។ ហេតុការណ៍នេះកំពុងកើតឡើងតាមរយៈការព្យាបាល ការឆែកពិនិត្យឈាម ការអប់រំយ៉ាងខ្លាំងក្លា ការស្រាវជ្រាវ ការហ្វឹកហ្វឺននិងផ្តល់ឱវាទ។

# តើខ្ញុំអាចទទួលពត៌មាននិងជំនួយពីទីណា?

**AIDSLINE**
ទូរស័ព្ទ: (03) 9347 6099, 1800 133 392,
1800 032 665 (TTY)
ម៉ោង: ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ 9.00 ព្រឹកដល់ 10.00 យប់
ថ្ងៃសៅរ៍និងអាទិត្យ 11.00 ព្រឹកដល់ 2.00 រសៀល,
7.00 យប់ដល់ 10.00 យប់។
សេវា(កិច្ចបំរើ)ផ្តល់ឱវាទ ពត៌មាន និងការបញ្ជូនតាមទូរស័ព្ទ។

**Melbourne Sexual Health Centre**
580 Swanston Street, Carlton 3053
ទូរស័ព្ទ: (03) 9347 0244 (រួមទាំង TTY), 1800 032 017
ការធ្វើតេស្ត ពត៌មាន ការអប់រំ ការផ្តល់ឱវាទ ការព្យាបាល ដោយមិនមានគិតថ្លៃ។
សូមធ្វើការណាត់ជួប។

**Victorian AIDS Council/Gay Men's Health Centre**
6 Claremont Street, South Yarra 3141
ទូរស័ព្ទ: (03) 9865 6700, 9827 3733 (TTY),
1800 134 840
ពត៌មាន ធនធាន ការបញ្ជូន ការអប់រំ ការគាំទ្រ ការផ្តល់ឱវាទ ការធ្វើតេស្ត ការព្យាបាល។

**Positive Living Centre/People Living with HIV/AIDS**
46 Ackland Street, St Kilda 3182
ទូរស័ព្ទ: (03) 9525 5866
ការគាំទ្រចំពោះអ្នកកើតឬអ្នកប៉ះពាល់ដោយ HIV/AIDS ។

**The Centre Clinic**
**c/- Northcote Community Health Centre**
42 Separation Street, Northcote 3070
ទូរស័ព្ទ: (03) 9481 7155
សេវាព្យាបាល។

**STD/Blood-Borne Virus Program**
Department of Human Services
GPO Box 4057, Melbourne 3001
ទូរស័ព្ទ: (03) 9616 7777
ពត៌មាន ការបញ្ជូន ធនធាន។

**Infectious Diseases & Microbiology Service**
**Alfred Hospital**
Commercial Road, Prahran 3181
ទូរស័ព្ទ: (03) 9276 2000
សេវា HIV/AIDS ការព្យាបាលអ្នកជំងឺក្នុង/ក្រៅមន្ទីរពេទ្យ ការធ្វើតេស្ត។

**Infectious Diseases Service**
**Royal Melbourne Hospital**
Grattan Street, Parkville 3052
ទូរស័ព្ទ: (03) 9342 7000
អ្នកជំងឺក្នុង/ក្រៅមន្ទីរពេទ្យ ការព្យាបាល ការធ្វើតេស្ត។

**Communicable Diseases Service**
**Royal Women's Hospital**
132 Grattan Street, Carlton 3053
ទូរស័ព្ទ: (03) 9344 2000
អ្នកជំងឺក្នុង/ក្រៅមន្ទីរពេទ្យ ការព្យាបាល ការធ្វើតេស្ត ការស្រាវជ្រាវ។

**STD Clinic**
**Western General Hospital**
Gordon Street, Footscray 3011
ទូរស័ព្ទ: (03) 9319 6666
អ្នកជំងឺក្នុង/ក្រៅមន្ទីរពេទ្យ ការព្យាបាល ការធ្វើតេស្ត។

**Sexual Health Clinic**
**Mornington Peninsula Hospital**
Hastings Road, Frankston 3199
ទូរស័ព្ទ: (03) 9784 7777
អ្នកជំងឺក្នុង/ក្រៅមន្ទីរពេទ្យ ការព្យាបាល ការធ្វើតេស្ត។

**Haemophilia Foundation Australia**
860 Nepean Highway, Moorabbin 3189
ទូរស័ព្ទ: (03) 9555 7595
**ព័ត៌មាន ការគាំទ្រចំពោះអ្នកមានឈាមមិនងាយកក។**

**Victorian Intravenous Drug Users AIDS Group (VIVAIDS)**
765A Nicholson Street, North Carlton 3054
ទូរស័ព្ទ: (03) 9381 2286
**ព័ត៌មាន ការអប់រំ ធនធាន។**

**Family Planning Victoria**
901 Whitehorse Road, Box Hill 3128
ទូរស័ព្ទ: (03) 9257 0100
**ព័ត៌មាន ការអប់រំ ការផ្តលឱវាទ ការធ្វើតេស្ត ការព្យាបាល។**

**Action Centre (for Youth)**
277 Flinders Lane, Melbourne 3000
ទូរស័ព្ទ: (03) 9654 4766, 1800 013 952
**ព័ត៌មាន ការអប់រំ ការផ្តល់ឱវាទ ការធ្វើតេស្ត ការព្យាបាល។**

## Rural STD clinical services

**Sexual Health Family Planning Clinic**
**The Annexe**
**Ballarat CHC**
105 Humffray Street South, Ballarat 3350
ទូរស័ព្ទ: (03) 5333 1635

**STD Clinic**
**Bendigo CHS**
Seymoure Street, Eaglehawk 3556
ទូរស័ព្ទ: (03) 5434 4300

**STD Clinic**
**Geelong CHS**
40 Little Malop Street, Geelong 3220
ទូរស័ព្ទ: (03) 5221 4735

**STD Clinic**
**Vermont Street Health Clinic**
4 Benson Court, Wodonga 3690
ទូរស័ព្ទ: (02) 6056 1589

**STD Clinic**
**Outpatient Department**
**Latrobe Regional Hospital**
Princes Highway, Traralgon 3844
ទូរស័ព្ទ: (03) 5174 9800

បោះផ្សាយដោយ STD/Blood-Borne Virus Program, Public Health Branch, Victorian Government Department of Human Services.

លិខិតខ្លីនេះគឺផ្អែកទៅលើព័ត៌មានចុងក្រោយបំផុត ដែលមាននៅខែមករា ឆ្នាំ 1998 ។

និពន្ធដោយ Wordsense.

គូសរៀបរៀងដោយ Outsource Design. (WS006F) 96/0514G

អាសយដ្ឋានក្នុង Internet: http://hna.ffh.vic.gov.au/phb